## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# ប្រព័ន្ធកិច្ចការពារកុមារ
# ឆ្នាំ២០១៩-២០២៩

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

**មាតិកា**

**អារម្ភកថា** .......... i

**១. សេចក្ដីផ្ដើម** .......... ១

១.១. ការវិភាគស្ថានភាព .......... ១

១.១.១. ទិដ្ឋភាពរួម .......... ១

១.១.២. បញ្ហាប្រឈម .......... ២

១.២. ទស្សនាទាននៃប្រព័ន្ធកិច្ចការពារកុមារ .......... ៣

១.២.១. ភាពចាំបាច់នៃប្រព័ន្ធកិច្ចការពារកុមារ .......... ៣

១.២.២. តួនាទីរបស់រាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធក្នុងប្រព័ន្ធកិច្ចការពារកុមារ .......... ៤

១.២.៣. គោលការណ៍គ្រឹះនៃប្រព័ន្ធកិច្ចការពារកុមារ .......... ៥

១.៣. ក្របខ័ណ្ឌគោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារ .......... ៥

១.៣.១. ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ .......... ៦

១.៣.២. ការផ្ដល់ជំនួយនិងសេវា .......... ៦

១.៣.៣. ធនធានមនុស្សនិងហិរញ្ញវត្ថុ .......... ៧

១.៣.៤. ការផ្លាស់ប្ដូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តទៅលើកុមារ .......... ៧

**២. ចក្ខុវិស័យ** .......... ៨

**៣. គោលបំណងនិងគោលដៅ** .......... ៨

៣.១. គោលបំណង .......... ៨

៣.២. គោលដៅ .......... ៨

៣.២.១. អភិវឌ្ឍច្បាប់និងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព។ .......... ៩

៣.២.២. រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារ ឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ។ .......... ៩

៣.២.៣. អភិវឌ្ឍធនធានមនុស្ស ក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ។ .......... ៩

៣.២.៤. លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្ដូរឥរិយាបថសង្គម ក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង។ .......... ៩

៣.២.៥. ផ្ដល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្ដែង។ .......... ៩

**៤. យុទ្ធសាស្ត្រ** .......... ៩

៤.១. ក្នុងគោលដៅអភិវឌ្ឍច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ យើងមានយុទ្ធសាស្ត្រសំខាន់ដូចខាងក្រោម៖ .......... ៩

៤.២. ក្នុងគោលដៅរៀបចំប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យទៅតាមប្រភេទកិច្ចការពារនីមួយៗ នៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធនឹងកុមារ យើងមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖ .......... ១០

៤.២.១. ការកំណត់អាទិភាពនៃកិច្ចការពារតាមលក្ខណៈភូមិសាស្ត្រ .......... ១០

៤.២.២. ការកំណត់អាទិភាពនៃកិច្ចការពារតាមវ័យនិងភេទ .......... ១០

៤.២.៣. ការកំណត់អ្នកទទួលខុសត្រូវនាំមុខនិងទទួលខុសត្រូវពាក់ព័ន្ធជាប្រព័ន្ធ .......... ១០

៤.៣. ក្នុងគោលដៅកសាងធនធានមនុស្ស ទាំងសមត្ថភាពការងារក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ទាំងចំនួននៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធសម្រាប់កិច្ចការពារកុមារ ជាពិសេសនៅតាមឃុំ សង្កាត់ និងភូមិ យើងមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖ ........ ១២
៤.៣.១. ការកសាងធនធានមនុស្ស ........ ១២
៤.៣.២. ការអប់រំផ្សព្វផ្សាយនិងការបណ្តុះបណ្តាល ........ ១៣
៤.៣.៣. ការកៀរគរធនធានហិរញ្ញវត្ថុ ........ ១៣
៤.៤. ក្នុងគោលដៅលើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គម ក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង យើងមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖ ........ ១៣
៤.៤.១. ការលើកកម្ពស់ការយល់ដឹងអំពីការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ ........ ១៣
៤.៤.២. ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ ........ ១៤
៤.៥. ចំពោះកិច្ចការពារកុមារឱ្យសមស្របតាមការជាក់ស្តែង ជាករណីដែលត្រូវការកិច្ចការពារមួយឬច្រើន តាមដំណាក់បន្តបន្ទាប់ឬនៅពេលតែមួយ ដែលយើងបានកំណត់ជាគោលដៅមួយត្រូវធ្វើសម្រេចទៅតាមគោលបំណងរបស់យើង យើងអាចដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖ ........ ១៤
៤.៥.១. ការកាត់បន្ថយបញ្ហាប្រឈមជាអាទិភាពរបស់កុមារ ........ ១៤
៤.៥.២. ការអនុវត្តកិច្ចការពារបញ្ចូលគ្នា ........ ១៤
**៥. ផែនការសកម្មភាព** ........ ១៥
៥.១. ការបង្កើតយន្តការ ........ ១៥
៥.២. ការបង្កើតក្របខ័ណ្ឌគតិយុត្ត ........ ១៥
៥.៣. ការគាំទ្រហិរញ្ញវត្ថុ ........ ១៦
៥.៤. ការបណ្តុះបណ្តាលធនធានមនុស្ស ........ ១៦
៥.៥. ដំណើរការអនុវត្តគម្រោង ........ ១៦
**៦. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ........ ១៦
**៧. សេចក្តីសន្និដ្ឋាន** ........ ១៧
**៨. សន្ធានុក្រម** ........ ១៧
**ឧបសម្ព័ន្ធ** ........ ១៩

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ ធ្លាប់រងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរបង្កឡើងដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានកាប់សម្លាប់ប្រជាជនអស់រាប់លាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវរងនូវការកាប់សម្លាប់ ការធ្វើទារុណកម្មគ្រប់បែបយ៉ាង ដែលធ្វើឱ្យកម្ពុជាបាត់បង់ធនធានមនុស្សជាច្រើន។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ រាជរដ្ឋាភិបាលបានខិតខំស្តារប្រទេសពីបាតដៃទទេ។ ទន្ទឹមនឹងការស្តារនិងអភិវឌ្ឍន៍ប្រទេសពីបាតដៃទទេ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិរបស់កុមារត្រូវបានការពារនិងលើកតម្កើង ដោយចាត់ទុកកុមារជាអ្នកបន្តវេនរបស់ប្រទេសជាតិ ដូចពាក្យស្លោកថា **«កុមារជាទំពាំងស្នងឫស្សី»** និង **«កុមារជាសសរទ្រូងសម្រាប់ប្រទេសជាតិ»**។

បច្ចុប្បន្ន រាជរដ្ឋាភិបាលបានបោះជំហានទៅមុខក្នុងការស្តារសង្គមនិងសេដ្ឋកិច្ចឡើងវិញ ដែលតម្រូវឱ្យកសាងធនធានមនុស្ស ជំនាញ និងប្រជាជនឱ្យមានសុខភាពល្អក្នុង២ទសវត្សចុងក្រោយនេះ ដោយមានកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ៧%។ រាជរដ្ឋាភិបាលបាននិងកំពុងវិភាជធនធានបន្ថែមទៀតដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀតដែលទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារ សំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ដែលក្នុងនោះបានផ្តោតសំខាន់លើការអភិវឌ្ឍសុខុមាលភាពកុមារផងដែរ។

ស្របតាមស្ថានភាពកុមារមានភាពរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន ជាអាទិ៍អនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២ អនុសញ្ញាលេខ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការនៅឆ្នាំ១៩៩៩ អនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅឆ្នាំ២០០៥ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧។

ក្នុងនាមជាប្រទេសដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ និងផែនការអភិវឌ្ឍន៍តាមវិស័យ រយៈពេលវែងនិងមធ្យមផ្សេងៗទៀត ដើម្បីធានាការអភិវឌ្ឍ ផ្តល់ការងារសមស្រប សមភាព ប្រសិទ្ធភាព និងធានាឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ រួមទាំងបង្កើតយន្តការជាច្រើននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួលដល់ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត រួមទាំងគោលនយោបាយនិងផែនការសកម្មភាពដូចបានបញ្ជាក់ខាងលើ។

ទន្ទឹមនឹងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការជាតិជាច្រើនទាក់ទងទៅនឹងការលើកកម្ពស់និងការការពារសិទ្ធិកុមារ កុមារកម្ពុជានៅតែជួបបញ្ហាប្រឈមមួយចំនួននៅឡើយដូចជា អំពើហិង្សាលើ

កុមារ ការកេងប្រវ័ញ្ចនិងការជួញដូរកុមារ ការប្រើប្រាស់គ្រឿងញៀននិងសារធាតុញៀន កុមារបម្លាស់ទី កុមាររងផលប៉ះពាល់ដោយការធ្វើចំណាកស្រុក កុមារបោះបង់ការសិក្សា កុមារកង្វះអាហារូបត្ថម្ភជាដើម ដែលតម្រូវឱ្យក្រសួង ស្ថាប័ន អាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សហគមន៍ ឪពុកម្តាយ រួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលានិងចំគោលដៅ។

យោងតាមបរិបទខាងលើ រាជរដ្ឋាភិបាលបានបង្កើតគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ដែលបន្សឹយន្តការដែលមានស្រាប់និងបន្តអនុវត្តឱ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីផ្តល់សេវាប្រកបដោយសង្គតិភាពសម្រាប់កុមារនិងគ្រួសារកុមារ ដែលរាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តនាពេលដ៏ខ្លីខាងមុខ ដើម្បីធានាថាបញ្ហាកុមារត្រូវបានដាក់បញ្ចូលទៅគ្រប់វិស័យពាក់ព័ន្ធក្នុងការលើកកម្ពស់សិទ្ធិ សុវត្ថិភាព ស្ថានភាព និងជំនាញរបស់កុមារ។ នេះគឺជាជំហានថ្មីមួយទៀតក្នុងការវិនិយោគជាមួយកុមារ ដោយសារការវិនិយោគលើកុមារនៅថ្ងៃនេះ នឹងបង្កើតបានជាធនធានមនុស្សដែលមានជំនាញនិងប្រកបដោយសក្តានុពលនាពេលអនាគត ដើម្បីធានាចីរភាពកំណើនសេដ្ឋកិច្ចជាតិនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។

គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ បានកំណត់នូវសសរស្តម្ភជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៣ ដោយផ្តោតទៅលើ **ការបង្ការនិងទប់ស្កាត់ ការអន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតប** ជាមួយគ្នានេះដែរក៏បានកំណត់នូវសកម្មភាពជាក់លាក់សម្រាប់ក្រសួងស្ថាប័នដែលបំពេញការងារក្នុងការលើកកម្ពស់សិទ្ធិកុមារ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ។ ខ្ញុំស្នើឱ្យគ្រប់ស្ថាប័នពាក់ព័ន្ធធ្វើការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់កុមារ ហើយតាមរយៈការអនុវត្តគោលនយោបាយនេះ កុមារកម្ពុជាកាន់តែទទួលបាននូវការផ្តល់សេវា និងការយកចិត្តទុកដាក់ជាពហុវិស័យបន្ថែមទៀត មានន័យថាធ្វើសកម្មភាពផ្សេងៗគ្នាដើម្បីឈានទៅសម្រេចគោលបំណងរួមតែមួយ។

ខ្ញុំសូមកោតសរសើរចំពោះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួង ស្ថាប័ន គណៈកម្មការការពារកុមារថ្នាក់ជាតិ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍ ដែលបានរួមចំណែកដល់ការរៀបចំកសាងគោលនយោបាយជាតិដ៏មានសារៈសំខាន់ ដែលជាស្នាដៃទុកជាប្រវត្តិសាស្ត្រសម្រាប់កុមារកម្ពុជា។ ខ្ញុំសូមលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន អាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សហគមន៍ ឪពុកម្តាយ ក្នុងការចាប់ផ្តើមអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ចាប់ពីពេលនេះតទៅ ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កម្ពុជាយើងនឹងអាចដោះស្រាយបញ្ហាប្រឈមទាំងអស់នេះបានដោយជោគជ័យ។

ខ្ញុំសូមស្នើដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងស្ថាប័នពាក់ព័ន្ធលើកគម្រោងចំណាយនានា ដើម្បីអនុវត្តសកម្មភាពអាទិភាពដែលមានចែងនៅក្នុងគោលនយោបាយជាតិនេះ និងដាក់បញ្ចូលទៅក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នរបស់ខ្លួន ជាពិសេស សូមយកចិត្តទុកដាក់រៀបចំឱ្យមានបុគ្គលិកឬភ្នាក់ងារសង្គមកិច្ច នៅតាមឃុំ សង្កាត់ ទូទាំងប្រទេស ដើម្បីដោះស្រាយបញ្ហាកិច្ចការពារកុមារ។

ខ្ញុំសូមស្នើឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារពង្រឹងតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការសម្របសម្រួលការងារអន្តរក្រសួងលើវិស័យកុមារ ជាពិសេស ការងារពិនិត្យតាមដាន វាយតម្លៃ និងធ្វើរបាយការណ៍អំពីស្ថានភាពនៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ។ 

ខ្ញុំសង្ឃឹមនិងជឿជាក់ថា ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ នឹងដាក់បញ្ចូលសកម្មភាពនានាដែលមានចែងនៅក្នុងគោលនយោបាយជាតិនេះទៅក្នុងផែនការប្រតិបត្តិតាមវិស័យរបស់ខ្លួន ដើម្បីពង្រឹង ការពារ និងលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នរួចហើយនៅឆ្នាំ១៩៩២ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ចាប់ពីពេលនេះតទៅ។

ថ្ងៃ សុក្រ ៨កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០២០

**ហ៊ុន សែន**

# ១. សេចក្តីផ្តើម

## ១.១. ការវិភាគស្ថានភាព

### ១.១.១. ទិដ្ឋភាពរួម

កម្ពុជាជាប្រទេសដែលមានប្រជាជនវ័យក្មេងច្រើន ដោយប្រជាជនប្រមាណពាក់កណ្តាលមានអាយុតិចជាង ២៥ឆ្នាំ តែទោះជាយ៉ាងនេះក្តីក៏អត្រាកំណើនប្រជាជនមាននិន្នាការកើនឡើងជាបន្តបន្ទាប់ ត្រូវនឹង១៤,១% រយៈពេល ១១ឆ្នាំ រវាងឆ្នាំ២០០៨និងឆ្នាំ២០១៩[៩]។ កំណើនប្រជាជនវ័យក្មេងនេះ ប្រសិនបើមានការវិនិយោគគ្រប់គ្រាន់លើធនធានមនុស្ស សុខាភិបាល និងកិច្ចការពារកុមារ នឹងបង្កើតបានជាស្នូលនៃផលលាភប្រជាសាស្ត្រ ដែលជាផលប្រយោជន៍សង្គមសេដ្ឋកិច្ច។ ការធ្លាក់ចុះនៃអត្រាលទ្ធភាពផ្តល់កំណើតសរុប នឹងកាត់បន្ថយផលធៀបពឹងផ្អែកសេដ្ឋកិច្ចនៅរយៈពេលពាទសវត្សបន្ទាប់ ដែលនាំមកនូវចំណូលខ្ពស់និងចូលរួមចំណែកដល់កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)។

កត្តាគ្រោះមហន្តរាយ ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក ការទុកកូនចោល និងការជាប់ពន្ធនាគាររបស់ឪពុកម្តាយ ជាហេតុធ្វើឱ្យកុមារទទួលរងនូវបញ្ហាប្រឈមនានា រួមមាន កុមារបែកចេញពីគ្រួសារ ការជួញដូរ អំពើហិង្សា ការគំរាមកំហែង ការរំលោភបំពានទាំងផ្លូវកាយ ផ្លូវចិត្តនិងផ្លូវភេទ ទាំងការកេងប្រវ័ញ្ចគ្រប់ទម្រង់។

តាមការអង្កេតនៅឆ្នាំ២០១៣ដោយក្រសួងកិច្ចការនារីនិងអង្គការយូនីសេហ្វស្តីពីអំពើហិង្សាលើកុមារបានឱ្យដឹងថា កុមារម្នាក់ក្នុងចំណោមពីនាក់បានទទួលរងអំពើហិង្សាលើរាងកាយ កុមារម្នាក់ក្នុងចំណោម៤នាក់ បានទទួលរងអំពើហិង្សាលើផ្លូវចិត្ត ហើយកុមារម្នាក់ក្នុងចំណោម២០នាក់ បានទទួលរងអំពើហិង្សាលើផ្លូវភេទ។ ការសិក្សានោះក៏បានបង្ហាញដែរថា អ្នកដែលរំលោភបំពានលើកុមារ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុត ដូចជា ឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំកុមារជាដើម។ យោងទៅតាមលទ្ធផលស្រាវជ្រាវនេះបានបញ្ជាក់ថា កុមារនៅក្នុងប្រទេសកម្ពុជានៅមិនទាន់មានសុវត្ថិភាពនិងការអភិវឌ្ឍពេញលេញនៅឡើយទេ។ ដូច្នេះ ឪពុកម្តាយ អាណាព្យាបាល និងអ្នកថែទាំគួរសិក្សាស្វែងយល់ពីអំពើហិង្សាលើកុមារនិងផលប៉ះពាល់លើកុមារ គ្រួសារ សង្គមជាតិ សេដ្ឋកិច្ចក្នុងគ្រួសារ ក៏ដូចសេដ្ឋកិច្ចប្រទេសជាតិដែរ។ ការយល់ដឹងអំពីផលប៉ះពាល់នេះ អាចជួយឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំបញ្ឈប់អំពើហិង្សានិងការមិនអើពើលើកុមារ។ បន្ថែមពីលើនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីទទួលបានការគាំទ្រក្នុងការការពារកុមារពីអំពើហិង្សាគ្រប់ទម្រង់ រួមទាំងការមិនអើពើលើកុមារដែលអាចកើតមានឡើងទាំងនៅខាងក្នុងនិងក្រៅផ្ទះ។

យោងតាមលទ្ធផលការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារនៅឆ្នាំ២០១៣របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានបង្ហាញថា ចំនួនកុមារសរុបអាយុ៥-១៧ឆ្នាំ នៅកម្ពុជាមាន៣ ៩៥៦ ៧៥១នាក់ នៅទូទាំងប្រទេស។ កុមារចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចមានចំនួន៧៥៥ ២៤៥នាក់ ក្នុងចំណោមកុមារជិត៤លាននាក់ អាយុ១៥-១៧ឆ្នាំ (ប្រមាណ៨១% មិនធ្វើការ និង១៩% បានទៅធ្វើការ។ កុមារ៦%ស្ថិតក្នុងការងារប្រកបដោយគ្រោះថ្នាក់ ៤,៩% នៅក្នុងទម្រង់ផ្សេងៗនៃពលកម្មកុមារ និង៨,២% ធ្វើការក្នុងលក្ខខណ្ឌការ[illegible]ដោយ

[៩] ការអង្កេតកម្លាំងពលកម្មនិងពលកម្មកុមារ ឆ្នាំ២០១២

សុវត្ថិភាព។ គិតមកត្រឹមឆ្នាំ២០១២ ពលកម្មកុមារមានត្រឹម៤២៩ ៣៨០នាក់ រីឯទម្រង់ធ្ងន់ធ្ងរបំផុត ឬកុមារធ្វើពលកម្មប្រកបដោយគ្រោះថ្នាក់មានចំនួន២៣៦ ៤៩៨នាក់ និងកុមារធ្វើការប្រកបដោយសុវត្ថិភាពមានចំនួន៣២៥ ៨៦៥នាក់។[២]

យោងតាមការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៧ បានបង្ហាញថា កុមារចូលរួមសកម្មភាពសេដ្ឋកិច្ច៧៣ម៉ឺននាក់ ស្មើ១៧% នៃចំនួនកុមារជិត៤,៣លាននាក់ ពលកម្មកុមារអាចថយចុះមកត្រឹមរង្វង់៣០ម៉ឺននាក់ នៅក្នុងចំណោម កុមារជិត៤៤ម៉ឺននាក់ដែលមិនបានចូលរៀន។[៣]

អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រនៅកម្ពុជាឆ្នាំ២០១៣ ផ្អែកលើនិយមន័យទូទៅបង្ហាញថា សមាមាត្រនៃពលកម្មកុមារសរុបមានប្រមាណ៩,៩% ដោយមានក្មេងប្រុសចំនួន៩,៣%និងក្មេងស្រីចំនួន១០,៧% គិតជាចំនួនមានប្រមាណ៣៥៦ ៩៣២នាក់នៃពលកម្មកុមារក្នុងកម្លាំងពលកម្ម។

យោងតាមរបាយការណ៍ស្តីពីការកំណត់ទីតាំង កន្លែងថែទាំកុមារក្នុងរាជធានី ខេត្តទាំង២៥នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៧ មានកន្លែងថែទាំកុមារចំនួន៦៣៩កន្លែង ដែលមានកុមារនិងយុវជនចំនួន៣៥ ៣៧៤នាក់ ក្នុងនោះកុមារដែលមានអាយុពី០ដល់១៧ឆ្នាំ ចំនួន២៦ ១៨៧នាក់ (ស្រី១២ ៥២៦នាក់)។ យោងតាមរបាយការណ៍នេះ មណ្ឌលថែទាំកុមារមានចំនួន៤០៦កន្លែង មានកុមារសរុបចំនួន១៦ ៥៧៩នាក់ ក្នុងនោះ មណ្ឌលរដ្ឋមានចំនួន២២ មណ្ឌល មានកុមារនិងយុវជនចំនួន១ ៦០១នាក់ (ស្រី៧២៤នាក់)។ កន្លែងថែទាំកុមារនៅតាមសហគមន៍ រួមមានផ្ទះស្នាក់នៅបណ្តោះអាសន្ន២៥កន្លែង មានកុមារចំនួន៦២៨នាក់ (ស្រី៣៤៨នាក់) ផ្ទះស្នាក់នៅជាក្រុម៧១កន្លែង មានកុមារ១ ៥៩២នាក់ (ស្រី៨២០នាក់) ក្រៅពីនោះ កុមារមួយចំនួនកំពុងស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន ទីវត្តអារាម និងទីកន្លែងសាសនា ១៣៧កន្លែង មានកុមារចំនួន៧ ៣៨៨នាក់ (ស្រី៣ ៥៨២នាក់)។ កុមារទាំងនេះសុទ្ធតែទទួលបាននូវសេវាស្នាក់នៅ អប់រំ ចិញ្ចឹមបីបាច់ថែរក្សាបង្កលក្ខណៈឱ្យរៀនសូត្រចំណេះដឹងទូទៅ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បង្រួបបង្រួមគ្រួសារ និងធ្វើសមាហរណកម្មទៅរស់នៅក្នុងសហគមន៍វិញ។ ទោះបីជាស្ថានភាពសុខុមាលភាពរបស់កុមារមានភាពល្អប្រសើរយ៉ាងណាក៏ដោយ ក៏វានៅមិនទាន់បានឆ្លើយតបទៅនឹងកម្រិតជីវភាពរស់នៅ និងតម្រូវការជាក់ស្តែងរបស់កុមាររងគ្រោះនិងងាយរងគ្រោះ និងគ្រួសារនៅតាមសហគមន៍នៅឡើយ។ យើងសង្កេតឃើញថា កុមារទាំងនោះនៅតែប្រឈមនឹងបញ្ហាមួយចំនួន ជាអាទិ៍ការរំលោភបំពាន ការកេងប្រវ័ញ្ចគ្រប់ទម្រង់ អំពើហិង្សា សុខភាព អាហារូបត្ថម្ភ ការអប់រំ សង្គម អារម្មណ៍ផ្លូវចិត្ត និងការពង្រឹងផ្នែកសេដ្ឋកិច្ចនិងជីវភាពរស់នៅប្រចាំថ្ងៃ ដែលតម្រូវឱ្យមានការខិតខំបន្ថែមទៀត ដើម្បីឧត្តមប្រយោជន៍របស់កុមារ។

### ១.១.២. បញ្ហាប្រឈម

ទោះបីជារាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ដើម្បីដោះស្រាយបញ្ហាប្រឈម តាមរយៈការដាក់ចេញនូវច្បាប់ គោលនយោបាយ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានា និងដោយមានការចូលរួមចំណែកពីអ្នកពាក់ព័ន្ធក្នុងការជួយដល់កុមារយ៉ាងណាក៏ដោយ ក៏នៅមានកុមារមួយចំនួនកំពុងប្រឈមនឹងបញ្ហាជាច្រើន ដូចជា កុមារត្រូវបានគេជួញដូរ រំលោភបំពាន កេងប្រវ័ញ្ចផ្សេងៗ កុមារដែលត្រូវគេបោះបង់ចោល ការបោះបង់ការសិក្សា កង្វះអាហារូបត្ថម្ភ សុខភាព អនាម័យ ទឹកស្អាត អំពើហិង្សា ពលកម្មកុមារ កុមារធ្វើទេសន្តរប្រវេសន៍តាមឪពុកម្តាយ

[២] ប្រភព៖ ការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ ឆ្នាំ២០១២

[៣] ប្រភព៖ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៧

កុមារត្រូវឪពុកម្តាយធ្វើទេសន្តរប្រវេសន៍ កុមារញៀនសារធាតុញៀន កុមារគ្មានទីជម្រក កុមារពិការ កុមារទំនាស់នឹងច្បាប់ កុមារឬអ្នកអាណាព្យាបាលមានជំងឺរ៉ាំរ៉ៃជាដើម។

ជាគោលការណ៍ ការទុកដាក់កុមារក្នុងមណ្ឌលថែទាំជាជម្រើសចុងក្រោយនិងជាបណ្តោះអាសន្ន ប៉ុន្តែបច្ចុប្បន្ននេះការនាំកុមាររងគ្រោះទៅដាក់ក្នុងមណ្ឌលថែទាំដែលជាវិធីសាស្ត្រតាមបែបប្រតិកម្ម ជាបញ្ហាប្រឈមដ៏ធំ ពីព្រោះវាបានធ្វើឱ្យចំនួនមណ្ឌលថែទាំកុមារនិងកុមារមានការកើនឡើងយ៉ាងឆាប់រហ័ស។

កង្វះការរៀបចំនិងការទទួលបានសេវាទប់ស្កាត់សម្រាប់កុមារងាយរងគ្រោះមកពីអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់ ការមិនអើពើ និងការធ្វើអាជីវកម្ម ត្រូវបានផ្តល់ដោយអ្នកពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់ ដែលជាបញ្ហាប្រឈមដ៏ធំដល់ដំណើរការនៃការអនុវត្តកិច្ចការពារកុមារដែលមានលក្ខណៈជាប្រព័ន្ធ។ ជាការពិត គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) និងអង្គការសង្គមស៊ីវិលមួយចំនួន បានត្រឹមតែអនុវត្តវិធានការផ្លូវការ ដែលរួមមានការបញ្ជូនទៅមណ្ឌលសុខភាព ការរាយការណ៍អំពីករណី និងការដោះស្រាយសម្រុះសម្រួលជាមួយជនល្មើសនិងកុមាររងគ្រោះត្រឹមតែថ្នាក់មូលដ្ឋានប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ យុទ្ធនាការនៃការអប់រំផ្សព្វផ្សាយ ការទប់ស្កាត់ ការផ្តល់ប្រឹក្សាយោបល់ទាំងផ្នែកច្បាប់និងសង្គម ការគាំទ្រ និងការថែទាំកុមារនៅក្នុងគ្រួសារ និងក្នុងសហគមន៍ នៅមានកម្រិតនិងមិនទាន់ដោះស្រាយបានចំគោលដៅនៅឡើយ។

បញ្ហាកុមាររងគ្រោះតែងតែកើតមានឡើងស្ទើរគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ជាពិសេសនៅតំបន់ដាច់ស្រយាល ដែលបញ្ហានេះបណ្តាលមកពីកង្វះព័ត៌មាន ចំណេះដឹង ការអប់រំ ទំនាក់ទំនង និងការផ្លាស់ប្តូរឥរិយាបថក្នុងចំណោមប្រជាជនទូទៅនិងអាជ្ញាធរមូលដ្ឋាន។ ក្នុងការបំពេញតួនាទីភារកិច្ចជាពហុវិស័យរបស់អាជ្ញាធរ សមត្ថកិច្ច អាជ្ញាធរដែនដី ព្រមទាំងអ្នកពាក់ព័ន្ធបាននិងកំពុងប្រឈមបញ្ហាជាច្រើនដូចជា អាណត្តិភាពនៃតួនាទីភារកិច្ចនិងការទទួលខុសត្រូវ កង្វះធនធាន កង្វះបទពិសោធ និងសមត្ថភាពបច្ចេកទេសសម្របសម្រួលដោះស្រាយបញ្ហាកិច្ចការពារកុមារ ជាពិសេសវិធីសាស្ត្រក្នុងការបង្ការទប់ស្កាត់ជាដើម។

## ១.២. ទស្សនាទាននៃប្រព័ន្ធកិច្ចការពារកុមារ

### ១.២.១. ភាពចាំបាច់នៃប្រព័ន្ធកិច្ចការពារកុមារ

នៅក្នុងបរិបទនៃក្របខ័ណ្ឌនៅក្នុងគោលនយោបាយនេះ ប្រព័ន្ធកិច្ចការពារកុមារ សំដៅដល់គោលនយោបាយ កម្មវិធី សកម្មភាពរួមទាំងក្របខ័ណ្ឌគតិយុត្តនិងយន្តការដែលមានស្រាប់ ដែលត្រូវបានដំណើរការអនុវត្ត ដែលមានលក្ខណៈជាប្រព័ន្ធនិងប្រទាក់ក្រឡាគ្នា ដើម្បីបង្ការទប់ស្កាត់ ការអន្តរាគមន៍ ការផ្តល់សេវានិងការឆ្លើយតបដល់កុមារដែលកំពុងស្ថិតក្នុងហានិភ័យសេដ្ឋកិច្ច កុមាររងគ្រោះនិងងាយរងគ្រោះ ដែលបាននិងកំពុងទទួលរងនូវការជួញដូរ ការរំលោភបំពាន ការកេងប្រវ័ញ្ចផ្សេងៗ និងអំពើហិង្សាគ្រប់ទម្រង់។

ប្រព័ន្ធកិច្ចការពារកុមារ គឺជាការប្តេជ្ញាចិត្តខិតខំជាក់ស្តែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្លាប់អនុវត្តជាច្រើនមកហើយ និងចាំបាច់ត្រូវធ្វើការពង្រឹងនិងពង្រីកបន្ថែមទៀត។ កត្តាទាំងនេះទាមទារការយកចិត្តទុកដាក់កាន់តែខ្ពស់ពីរាជរដ្ឋាភិបាលទៅលើការអនុវត្តកិច្ចការពារកុមារដែលមានលក្ខណៈជាប្រព័ន្ធនៅកម្ពុជា រួមមាន៖

១- ភាពចាំបាច់ក្នុងការវិនិយោគបន្ថែម លើមន្ត្រីសង្គមកិច្ចឬបុគ្គលិកសង្គមនៅថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាការពារកុមារប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល សង្គតិភាព និងទាន់ពេលវេលាដល់កុមារនិងគ្រួសារនៅតាមសហគមន៍។

២- ការបន្តធានាឱ្យកុមារទទួលបាននូវសេវាផ្លូវច្បាប់និងសមធម៌សង្គម តាមរយៈការផ្តល់នូវកញ្ចប់អប្បរមានៃសេវាសង្គមកិច្ចសម្រាប់កុមារនិងគ្រួសារដែលត្រូវការកិច្ចការពារ។

៣- ការឆ្លើយតបចំពោះគ្រោះមហន្តរាយដែលបណ្តាលឱ្យមានផលប៉ះពាល់ដល់កុមារនិងគ្រួសារកុមារ។

៤- ការបន្តប្រមូលផ្តុំ ពង្រឹង និងពង្រីកកម្មវិធីដែលមានស្រាប់សម្រាប់កិច្ចការពារកុមារ សំដៅបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាពឱ្យបានទូលំទូលាយ។

៥- ការធានានូវសង្គតិភាពនៃនីតិវិធី វិធានការ និងយន្តការ ដែលមានស្រាប់ក្នុងការដោះស្រាយបញ្ហារបស់កុមារ ដើម្បីបំពេញនូវតម្រូវការនិងធានាការពារកុមារ ប្រកបដោយបរិយាកាសគ្រួសារ សេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់មានលក្ខណៈកុមារមេត្រី និងធានាឧត្តមប្រយោជន៍របស់កុមារ។

### ១.២.២- តួនាទីរបស់រាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធក្នុងប្រព័ន្ធកិច្ចការពារកុមារ

កត្តាចាំបាច់ខាងលើបញ្ជាក់ថា សកម្មភាពកិច្ចការពារកុមារជាប្រព័ន្ធ ត្រូវមានលក្ខណៈពហុវិស័យពាក់ព័ន្ធនឹងយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលមានតួនាទីទ្រទ្រង់ប្រព័ន្ធកិច្ចការពារកុមារតាមរយៈ (១)-ជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ ស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ លិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ (២)-វិភាជថវិកាដើម្បីទ្រទ្រង់ការអនុវត្តគោលនយោបាយ (៣)-រៀបចំនិងអនុវត្តក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ (៤)-កសាងសមត្ថភាពនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ។

#### ១- ជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៨ បានកំណត់ច្បាស់ថា រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលតែងផ្តោតការយកចិត្តទុកដាក់លើការគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំនិងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាពឬសុខុមាលភាពរបស់កុមារ។ ទន្ទឹមនឹងនេះ ដើម្បីធានាឧត្តមប្រយោជន៍របស់កុមារ កម្ពុជាបានផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិនិងពិធីសារបន្ថែមដែលពាក់ព័ន្ធនឹងកុមារជាច្រើនទៀត។

#### ២- ថវិកាដើម្បីទ្រទ្រង់ការអនុវត្តគោលនយោបាយ

ដោយមានកំណើនសេដ្ឋកិច្ចកើនឡើងរៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបានបង្កើនថវិកាលើវិស័យសង្គមកិច្ច អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម និងវិស័យមួយចំនួនទៀត ក្នុងគោលដៅធ្វើឱ្យសុខុមាលភាពប្រជាជនកាន់តែប្រសើរឡើង ជាពិសេសចំពោះកុមារ និងសម្រេចបានគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។ ប្រជាជនកម្ពុជា ជាពិសេសកុមារ បាននិងកំពុងទទួលផ្លែផ្កាពីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% នាអំឡុងពេលពីទសវត្សកន្លងមកនេះ។ អត្រាភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះជាលំដាប់ពីជាង៥៣%ក្នុងឆ្នាំ២០០៤ មកនៅត្រឹមរង្វង់១០% នាបច្ចុប្បន្ន។ លើសពីនេះទៀត ផ្លែផ្កានៃកំណើនសេដ្ឋកិច្ចក៏ត្រូវបានបែងចែកក្នុងលក្ខណៈកាន់តែមានសមធម៌ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការថយចុះ

នៃមេគុណវិសមភាពនៃការប្រើប្រាស់០,៤១ នៅឆ្នាំ២០០៧ មកនៅត្រឹម០,២៩ នៅឆ្នាំ២០១២ ជាមួយនឹងការរំពឹងថាតួលេខនេះនឹងបន្តថយចុះថែមទៀតនៅឆ្នាំខាងមុខ។

### ៣- រៀបចំនិងអនុវត្តក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ

ដោយយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះសិទ្ធិកុមារ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ និងបានដាក់ចេញនូវបទប្បញ្ញត្តិ គោលនយោបាយ និងផែនការសកម្មភាពជាតិ រួមទាំងយន្តការជាច្រើនទាក់ទងនឹងកិច្ចការពារកុមារ ដើម្បីជានាការអនុវត្តពេញលេញនូវគោលការណ៍និងបទប្បញ្ញត្តិនានារបស់អនុសញ្ញាស្តីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។ ជាមួយ នឹងការយកចិត្តទុកដាក់ចំពោះសិទ្ធិនិងសុខុមាលភាពកុមារ រាជរដ្ឋាភិបាលក៏បានចាត់បញ្ហាកុមារជាបញ្ហាអាទិភាព ក្នុងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ខ្លួន។ អាជ្ញាធរមានសមត្ថកិច្ចដូចជាតុលាការឬអាជ្ញាធររដ្ឋបាល បានចាត់វិធានការនិងចេញសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារ ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។

### ៤- កសាងសមត្ថភាពនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ

រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវាការពារកុមារ។ សេវាការពារកុមារនៅក្នុងប្រទេសកម្ពុជា ត្រូវបានពង្រឹងកាន់តែប្រសើរឡើងតាមរយៈគម្រោងនិងកម្មវិធីកិច្ចសហប្រតិបត្តិការនានារបស់អង្គការសង្គមស៊ីវិល។ ក្នុងរយៈពេល២ទសវត្សកន្លងទៅនេះ ទីភ្នាក់ងារជាតិនិងអន្តរជាតិដែលធ្វើការងារពាក់ព័ន្ធនឹងកុមារ បានធ្វើឱ្យសម្រេចនូវសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការតស៊ូមតិដើម្បីកុមារ ទទួលបានសិទ្ធិការពារ ជួយកសាងសមត្ថភាពបុគ្គលិកសង្គមនៅគ្រប់កម្រិត និងផ្តល់សេវាដោយផ្ទាល់ដល់កុមារ គ្រួសារនិងសហគមន៍ងាយរងគ្រោះ។

### ១.២.៣- គោលការណ៍គ្រឹះនៃប្រព័ន្ធកិច្ចការពារកុមារ

នៅក្នុងបរិបទសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា និងនយោបាយដែលមានលក្ខណៈប្រទាក់ក្រឡា និងដើម្បីជានាឱ្យមានប្រព័ន្ធកិច្ចការពារកុមារបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព ក្នុងចក្ខុវិស័យសម្រាប់ការអភិវឌ្ឍយូរអង្វែង គោលនយោបាយនេះ គប្បីអនុលោមតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិកុមារសំខាន់ៗ ដូចខាងក្រោម៖

១- គោលការណ៍ឧត្តមប្រយោជន៍កុមារ។

២- គោលការណ៍មិនរើសអើង។

៣- គោលការណ៍សិទ្ធិរស់រានមានជីវិតនិងសិទ្ធិអភិវឌ្ឍន៍។

៤- គោលការណ៍គោរពទស្សនៈកុមារ។

## ១.៣- ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ

ប្រព័ន្ធកិច្ចការពារកុមារ គឺជាបណ្តុំនៃវិធានបង្កើតឡើងក្នុងគោលបំណងជំរុញនិងលើកកម្ពស់ការការពារកុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់ទម្រង់។ វិធានទាំងនេះរួមមាន (១)-ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ (២)-ការផ្តល់ជំនួយនិងសេវា (៣)-ធនធានមនុស្សនិងហិរញ្ញវត្ថុ និង(៤)-ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តទៅលើកុមារ ដែលវិធានទាំងនេះត្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសវិស័យសុខុមាលភាពសង្គម អប់រំ សុខភាព សន្តិសុខ និងយុត្តិធម៌ ក្នុងការគាំទ្រដល់ការបង្ការទប់ស្កាត់និងឆ្លើយតប ដើម្បីការពារកុមារពីហានិភ័យផ្សេងៗ។

# ការបង្កើតប្រព័ន្ធកិច្ចការពារកុមារ




### ១.៣.១- ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញឱ្យអនុវត្តនូវច្បាប់និងគោលនយោបាយដែលមានជាធរមានជាច្រើន មានលក្ខណៈវិជ្ជមាននិងស៊ីជម្រៅក្នុងការអនុវត្ត។ ជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវយុទ្ធសាស្ត្រនានាសម្រាប់លើកស្ទួយការអនុវត្តអនុសញ្ញា និងធ្វើការសម្របសម្រួលកិច្ចការពារកុមារ មានលក្ខណៈជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ។ ទោះបីច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកុមារមានច្រើន និងមានខ្លឹមសារល្អយ៉ាងណាក៏ដោយ ក៏សមត្ថភាពនៃការអនុវត្តនៅមានកម្រិតនៅឡើយ។

### ១.៣.២- ការផ្តល់ជំនួយនិងសេវា

ជាការពិត ការផ្តល់ជំនួយនិងសេវាទៅដល់កុមារនិងគ្រួសារដែលជួបប្រទះនឹងហានិភ័យ ត្រូវបានយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ដោយមានការចូលរួមគាំទ្រពីអង្គការ សមាគម សង្គមស៊ីវិល និងពីវិស័យឯកជន។ ការផ្តល់ជំនួយនិងសេវាទាំងនោះរួមមាន ការបង្ការទប់ស្កាត់ ជំនួយសង្គ្រោះបន្ទាន់ សេវាស្តារនីតិសម្បទា ប្រឹក្សាយោបល់ ផ្ស

សមាហរណកម្ម និងការពិនិត្យតាមដាន។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់សេវាទាំងនេះនៅមានកម្រិតលក្ខណៈរាយប៉ាយនិងមិនចំគោលដៅ។

### ១.៣.៣. ធនធានមនុស្សនិងហិរញ្ញវត្ថុ

ប្រព័ន្ធកិច្ចការពារកុមារប្រកបដោយប្រសិទ្ធភាព តម្រូវឱ្យមាននូវធនធានមនុស្សនិងហិរញ្ញវត្ថុចាំបាច់ ដើម្បីគាំទ្រការងារទាំងនោះ និងធានាថា កុមារទទួលបាននូវកិច្ចការពារប្រកបដោយសមភាពនិងសមធម៌។ រាជរដ្ឋាភិបាលបានវិនិយោគយ៉ាងច្រើនលើការកសាងសមត្ថភាពនិងការផ្តល់សេវាជួយដល់កុមារនិងគ្រួសាររងគ្រោះ និងងាយរងគ្រោះ។ ក្នុងនោះក៏មានការចូលរួមយ៉ាងសកម្មពីដៃគូពាក់ព័ន្ធ មានជាអាទិ៍ ដៃគូអភិវឌ្ឍ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ វិស័យឯកជន និងសប្បុរសជនផងដែរ។ ប៉ុន្តែ ទោះជាមានការវិនិយោគនិងការជួយជ្រោមជ្រែងពីអ្នកពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏ធនធានមនុស្សនិងធនធានថវិកាទាំងនោះមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារនិងគ្រួសារនៅឡើយ។

### ១.៣.៤. ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តទៅលើកុមារ

ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ពណ៌សម្បុរ ភេទ ភាសា នយោបាយឬទស្សនៈ ទ្រព្យសម្បត្តិ កំណើត ឋានៈនិងស្ថានភាពផ្សេងទៀតរបស់កុមារពាក់ព័ន្ធនឹងវិធីសាស្ត្របែបអវិជ្ជមានក្នុងការអប់រំ ទូន្មាន ប្រៀនប្រដៅកុមារ បានចាក់ឫសនៅក្នុងសង្គមខ្មែរ។ អំពើហិង្សាក្នុងគ្រួសារ សហគមន៍ សាលារៀន និងនៅទីកន្លែងដទៃទៀតតែងកើតមានឡើងដោយសារការមើលឃើញនិងរៀនត្រាប់តាមទង្វើដែលជាទម្លាប់មិនល្អ ដែលមនុស្សធំប្រព្រឹត្តទៅលើកុមារឬមនុស្សដែលមានឋានៈទាបជាង ជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍរបស់កុមារ។ ដោយមើលឃើញនូវបញ្ហាទាំងនេះ រាជរដ្ឋាភិបាល តាមរយៈក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនិងក្រសួងពាក់ព័ន្ធ បានប្តេជ្ញាចិត្តដាក់ចេញនូវវិធានការ និងយុទ្ធនាការផ្សេងៗក្នុងការជំរុញលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតនៃការប្រព្រឹត្តតាមបែបវិជ្ជមានដល់កុមារដែលជាម្ចាស់សិទ្ធិ គ្រួសារ សហគមន៍ និងអ្នកដែលមានកាតព្វកិច្ចអនុវត្តរួមទាំងតួអង្គពាក់ព័ន្ធនិងអ្នករៀបចំគោលនយោបាយ។

ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារផ្អែកលើសសរស្តម្ភ៣ គឺ (១)ការបង្ការទប់ស្កាត់ (២)ការអន្តរាគមន៍ (៣)ការផ្តល់សេវានិងការឆ្លើយតប ដែលយើងត្រូវបំពេញជាលក្ខណៈប្រព័ន្ធមួយ។ សសរស្តម្ភនីមួយៗមានទិដ្ឋភាពរួមរបស់វានិងមានបញ្ហាប្រឈមដែលនាំទៅដល់បង្កើតយុទ្ធសាស្ត្រ និងវិធានការឬសកម្មភាពផ្សេងៗគ្នាទៅតាមករណីខុសៗគ្នាដែលកើតមានឡើង។ រាល់សកម្មភាពទាំងនោះ នឹងត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌគោលនយោបាយជាតិទៅតាមក្របខ័ណ្ឌនិងផែនការសកម្មភាពពាក់ព័ន្ធដល់គ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធដែលចាំបាច់ត្រូវធ្វើការងារទាំងនោះស្របតាមគោលនយោបាយនេះ ដែលនឹងកំណត់នៅក្នុងផែនការសកម្មភាពនាពេលខាងមុខ។

ជារួម ក្របខ័ណ្ឌគោលនយោបាយជាតិនៃប្រព័ន្ធកិច្ចការពារកុមារនេះផ្តោតសំខាន់លើសសរស្តម្ភទាំង៣ គឺ ការបង្ការទប់ស្កាត់ ការអន្តរាគមន៍ ការផ្តល់សេវានិងការឆ្លើយតបជាពហុវិស័យទាន់ពេលវេលាចំពោះកុមារគ្រប់រូបដោយគ្មានការរើសអើង និងត្រូវឱ្យមានភាពប្រទាក់ក្រឡានិងស៊ីចង្វាក់គ្នា ចាប់ពីវិធានការបង្ការទប់ស្កាត់រហូតដល់ការឆ្លើយតបចំពោះកុមាររងគ្រោះ ឱ្យទទួលបានសុវត្ថិភាព ទាំងផ្លូវកាយ ផ្លូវចិត្ត និងសុខុមាលភាព។ ក្នុងនោះកុមារគ្រប់រូបត្រូវទទួលបានការការពារដោយច្បាប់ កុមាររងគ្រោះនិងគ្រួសារត្រូវទទួលបានសេវាសមស្រប ត្រូវមានធនធានមនុស្សនិងថវិកាគ្រប់គ្រាន់សម្រាប់កិច្ចការពារកុមារ និងត្រូវផ្លាស់ប្តូរឥរិយាបថសង្គមចំពោះការប្រព្រឹត្តទៅលើកុមារ។

ជារួម យើងអាចរៀបចំទម្រង់នៃប្រព័ន្ធកិច្ចការពារកុមារដូចខាងក្រោម៖




## ២. ចក្ខុវិស័យ

ចក្ខុវិស័យសម្រាប់អនាគតកម្ពុជា គឺធានាឱ្យកុមារគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសិទ្ធិស្មើៗគ្នា ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម មានសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវការការពារ សិទ្ធិអភិវឌ្ឍន៍ និងសិទ្ធិចូលរួម។

## ៣. គោលបំណងនិងគោលដៅ

### ៣.១. គោលបំណង

ដើម្បីសម្រេចនូវចក្ខុវិស័យខាងលើក្នុងជំហានរយៈពេល១០ឆ្នាំខាងមុខ ចាំបាច់ត្រូវយកចិត្តទុកដាក់លើកកម្ពស់កិច្ចការពារកុមារបន្ថែមទៀត តាមរយៈការពង្រឹងការអនុវត្តប្រព័ន្ធកិច្ចការពារកុមារមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នាពីគ្រប់ភាគីពាក់ព័ន្ធ សំដៅឆ្លើយតបទៅនឹងកិច្ចការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់ទម្រង់ ដើម្បីឧត្តមប្រយោជន៍កុមារ។

### ៣.២. គោលដៅ

ដើម្បីឈានទៅសម្រេចបាននូវគោលបំណងខាងលើ គោលដៅសំខាន់ៗសម្រាប់ការអនុវត្តក្នុងរយៈពេលខាងមុខមានដូចខាងក្រោម៖

៣.២.១- អភិវឌ្ឍច្បាប់និងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព។

៣.២.២- រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារ ឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ។

៣.២.៣- អភិវឌ្ឍធនធានមនុស្ស ក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ។

៣.២.៤- លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គម ក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង។

៣.២.៥- ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង។

## ៤- យុទ្ធសាស្ត្រ

ដើម្បីឱ្យសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនីមួយៗខាងលើ យុទ្ធសាស្ត្រសំខាន់ៗនៃប្រព័ន្ធកិច្ចការពារកុមារ គឺការផ្លាស់ប្តូរការយកចិត្តទុកដាក់ឆ្ពោះទៅរកការទប់ស្កាត់ និងការទទួលស្គាល់នូវតួនាទីបឋមរបស់គ្រួសារនិងសហគមន៍នីមួយៗ នៅក្នុងការធានានូវសុខុមាលភាពសម្រាប់កុមារ។ ក្នុងន័យនេះ គោលនយោបាយតម្រូវឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រនិងឥរិយាបថសម្រាប់កុមារ គ្រួសារនិងសហគមន៍ អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដី និងតួអង្គពាក់ព័ន្ធផ្សេងៗទៀត ដោយផ្អែកលើយុទ្ធសាស្ត្រសំខាន់ៗដែលជាគន្លឹះសម្រាប់ធ្វើឱ្យសម្រេចបាននូវគោលដៅនីមួយៗដែលយើងបានដាក់ចេញអនុវត្ត។

ក្របខ័ណ្ឌគោលនយោបាយជាតិនេះ ផ្តោតជាសំខាន់លើសសរស្តម្ភបីគឺ ការបង្ការទប់ស្កាត់ ការអន្តរាគមន៍ ការផ្តល់សេវានិងការឆ្លើយតប ដែលទាមទារឱ្យមានការអនុវត្តជាពហុវិស័យក្នុងទំនាក់ទំនងជាប្រព័ន្ធប្រទាក់ក្រឡាគ្នាមួយ ទាំងសមត្ថកិច្ចនិងភាគីពាក់ព័ន្ធដែលអនុវត្តវិធានការ ទាំងពេលវេលា ដើម្បីប្រយោជន៍ដល់កុមារ ដែលវាពិតជាផ្តល់លទ្ធផលពិតប្រាកដនិងល្អជាងការអនុវត្តដោយឡែកៗពីគ្នា និងមិនចំគោលដៅទៅលើវិធានការពារមួយ។

ព្រះរាជាណាចក្រកម្ពុជាយើងមានច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ដែលយើងអាចរៀបចំឱ្យមានការអនុវត្តជាប្រព័ន្ធតាមបែបយុទ្ធសាស្ត្រថ្មីជាពហុវិស័យ ដូចមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។

### ៤.១- ក្នុងគោលដៅអភិវឌ្ឍច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ យើងមានយុទ្ធសាស្ត្រសំខាន់ដូចខាងក្រោម៖

ការយល់ដឹងឱ្យបានច្បាស់លាស់អំពីខ្លឹមសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលយើងបានប្រមូលនិងចងក្រងកន្លងមកទៅតាមកិច្ចការពារនីមួយៗ មានសារៈសំខាន់ណាស់សម្រាប់ការអនុវត្ត រួមទាំងមន្ត្រីរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច វិស័យឯកជន អ្នកសារព័ត៌មាន និងបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលនៅគ្រប់រចនាសម្ព័ន្ធ។ នៅថ្នាក់ជាតិ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ មានតួនាទីចម្បង ដើម្បីស្វែងយល់មាត្រាឬប្រការនីមួយៗដែលចែងក្នុងច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត ឈានទៅអនុវត្តជាប្រព័ន្ធជាមួយភាគីពាក់ព័ន្ធនៅគ្រប់កម្រិតឱ្យទទួលបានលទ្ធផលល្អ ក៏ដូចជាផ្សព្វផ្សាយនិងការបណ្តុះបណ្តាល។

៤.២- ក្នុងគោលដៅរៀបចំប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យទៅតាមប្រភេទកិច្ចការពារនីមួយៗ នៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធនឹងកុមារ យើងមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

### ៤.២.១- ការកំណត់អាទិភាពនៃកិច្ចការពារតាមលក្ខណៈភូមិសាស្ត្រ

ផ្អែកលើការវិភាគស្ថានភាព(ចំណុច១.១) ត្រូវកំណត់ឱ្យបាននូវអាទិភាពនៃកិច្ចការពារនីមួយៗ រវាងភូមិសាស្ត្រខុសៗគ្នាដែលត្រូវយកចិត្តទុកដាក់ដូចជា នៅតំបន់ទីក្រុង ទីប្រជុំជន និងជនបទ ជាពិសេសតំបន់ជនជាតិដើមភាគតិចជាដើម។ ការកំណត់បានយ៉ាងនេះ អាចឱ្យគោលដៅរបស់យើងងាយសម្រេចបាន ទៅតាមសូចនាករ ដែលមានកំណត់នៅក្នុងផែនការសកម្មភាពជាជំហានៗ។

### ៤.២.២- ការកំណត់អាទិភាពនៃកិច្ចការពារតាមវ័យនិងភេទ

ផ្អែកលើការវិភាគស្ថានភាពនេះដែរ ត្រូវកំណត់ឱ្យបាននូវអាទិភាពនៃកិច្ចការពារនីមួយៗ ទៅតាមវ័យនិងភេទខុសៗគ្នាដែលត្រូវយកចិត្តទុកដាក់ ក្នុងនោះត្រូវភ្ជាប់ទៅនឹងប្រភេទរងគ្រោះឬងាយរងគ្រោះរបស់កុមារ។ គោលដៅរបស់យើងនឹងអាចសម្រេចបានតាមការកំណត់ នៅក្នុងសូចនាករតាមលំនាំយុទ្ធសាស្ត្រទី១ដែរ។

### ៤.២.៣- ការកំណត់អ្នកទទួលខុសត្រូវនាំមុខនិងទទួលខុសត្រូវពាក់ព័ន្ធជាប្រព័ន្ធ

ផ្អែកលើយុទ្ធសាស្ត្រទី១និងទី២ ត្រូវរៀបចំឱ្យមានប្រព័ន្ធអ្នកទទួលខុសត្រូវនាំមុខនិងអ្នកទទួលខុសត្រូវពាក់ព័ន្ធដែលត្រូវដោះស្រាយទៅតាមប្រភេទនៃកិច្ចការពារដោយផ្អែកលើសសរស្តម្ភទាំងបី ការបង្ការទប់ស្កាត់ ការអន្តរាគមន៍ ការផ្តល់សេវានិងការឆ្លើយតប ទៅតាមភូមិសាស្ត្រអាទិភាព តាមវ័យ ភេទ និងក្រុមគោលដៅ ទៅតាមប្រភេទកិច្ចការពារនិងភូមិសាស្ត្រនីមួយៗ។

## ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ

ប្រព័ន្ធអប់រំ : **ក្រសួងអប់រំ យុវជន និងកីឡា**

ប្រព័ន្ធផ្សព្វផ្សាយ : **ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសភាពាណិជ្ជកម្មកម្ពុជា**

វិស័យសាសនានិងទំនៀមទម្លាប់ជនជាតិដើមភាគតិច : **ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

យន្តការនៅថ្នាក់សហគមន៍ទាក់ទងនឹងស្ត្រីនិងកុមារ : **អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ**

ប្រព័ន្ធសុខុមាលភាពគ្រួសារនិងការចិញ្ចឹមកូនតាមបែបវិជ្ជមាន : **ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី**




## ប្រព័ន្ធអន្តរាគមន៍

យន្តការតុលាការ : **ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**

យន្តការនគរបាលយុត្តិធម៌ : **អគ្គស្នងការនគរបាលជាតិ បណ្ឌិត្យសភាននគរបាលកម្ពុជា កងរាជអាវុធហត្ថលើផ្ទៃប្រទេស**

យន្តការនៅថ្នាក់សហគមន៍ទាក់ទងនឹងស្ត្រីនិងកុមារ : **លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃក្រសួងមហាផ្ទៃ**




## ប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា

ប្រព័ន្ធសុខុមាលភាពកុមារនិងគ្រួសារ : **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ប្រព័ន្ធអប់រំ : **ក្រសួងអប់រំ យុវជន និងកីឡា**

ប្រព័ន្ធសុខាភិបាល : **ក្រសួងសុខាភិបាល**

ប្រព័ន្ធគាំពារសង្គម : **ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សភាពាណិជ្ជកម្មកម្ពុជា**

ប្រព័ន្ធរាយការណ៍ : **ក្រសួងមហាផ្ទៃ និងអគ្គស្នងការនគរបាលជាតិ**

ប្រព័ន្ធទូរសព្ទជំនួយ : **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

យន្តការភ្ជាក់ងារផ្តល់សេវាសង្គមកិច្ច : **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី**

យន្តការផ្តល់សេវាផ្នែកច្បាប់ : **ក្រសួងយុត្តិធម៌និងគណៈមេធាវីកម្ពុជា**

យន្តការឆ្លើយតបគ្រោះមហន្តរាយ : **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ កាកបាទក្រហមកម្ពុជា**




**៤.៣. ក្នុងគោលដៅកសាងធនធានមនុស្ស ទាំងសមត្ថភាពការងារក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ទាំងចំនួននៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធសម្រាប់កិច្ចការពារកុមារ ជាពិសេសនៅតាមឃុំ សង្កាត់ និងភូមិ យើងមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖**

**៤.៣.១. ការកសាងធនធានមនុស្ស**

ក្នុងគោលដៅទី១និងទី២ យុទ្ធសាស្ត្ររបស់យើងមានលក្ខណៈជាគោលការណ៍និងនីតិវិធីនៅឡើយ។ អ្នកដែលធ្វើឱ្យសម្រេចបាននូវបណ្តាយុទ្ធសាស្ត្រក្នុងគោលដៅទី១និងទី២នេះ គឺធនធានមនុស្សដែលយើងមានស្រាប់។ វិសាលភាពនៃកិច្ចការពារកុមារមានទំហំចាប់ពីកម្រិតទូទាំង ប្រទេសរហូតដល់ចែកជាតំបន់ជនបទនិងទីប្រជុំជនដែលបន្តចែកជាឃុំ សង្កាត់ ភូមិ និងចុងក្រោយបំផុតគឺខ្នងផ្ទះ ឬមណ្ឌលថែទាំកុមារ។ បើទោះបីជាយើងមានរចនាសម្ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងមានយន្តការដែលចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តសព្វគ្រប់ហើយក្តី បើយើងគ្មានធនធានមនុស្សទាំងចំនួន ទាំងសមត្ថភាពគ្រប់គ្រាន់ទេ យើងមិនរំពឹងទុកថានឹងអាចសម្រេចបានល្អនូវគោលដៅទាំងឡាយរបស់យើងឡើយ។ ចំពោះសមត្ថភាព យើងត្រូវខិតខំលើកកម្ពស់ជាចាំបាច់ដើម្បីឱ្យការអនុវត្តក្របខ័ណ្ឌច្បាប់មានលក្ខណៈងាយស្រួល ដែលកន្លងមកខ្លឹមសារច្បាប់មានអត្ថន័យខ្ពស់ជាងសមត្ថភាពធនធានមនុស្សរបស់យើងដែលត្រូវទទួលយកទៅអនុវត្ត។

បញ្ហាចោទរបស់យើងនាពេលបច្ចុប្បន្ន គឺកង្វះធនធានមនុស្សនៅថ្នាក់ឃុំ សង្កាត់ និងភូមិ។ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ គាត់ធ្វើការមានអាណត្តិ៥ឆ្នាំម្តងតាមការបោះឆ្នោត ហើយគាត់គ្មានបុគ្គលិកជំនួយទេ។ នៅភូមិស្ថានភាពនេះក៏មានលំនាំដូចគ្នាដែរ។ យុទ្ធសាស្ត្រនេះ ជាគន្លឹះនៅក្នុងគោលនយោបាយរបស់យើងដែលត្រូវតែទទួលបានការពិនិត្យរៀបចំឱ្យបានល្អ។ យើងអាចរកធនធានមនុស្ស ស្របតាមគោលនយោបាយជាតិ និងបទដ្ឋានគតិយុត្តិដែលមានជាធរមាន។

### ៤.៣.២- ការអប់រំផ្សព្វផ្សាយនិងការបណ្ដុះបណ្ដាល

ការអប់រំផ្សព្វផ្សាយនិងការបណ្ដុះបណ្ដាល ជាយុទ្ធសាស្ត្របំពេញនូវសមត្ថភាពឱ្យធនធានមនុស្សរបស់យើង។ ដូច្នេះ លទ្ធផលនៃកិច្ចការពារត្រូវពឹងផ្អែកលើយុទ្ធសាស្ត្រទី១ខាងលើនេះនិងសមត្ថភាពរបស់ពួកគាត់។ លក្ខណៈជាប្រព័ន្ធនៃធនធានមនុស្សសម្រាប់គោលនយោបាយជាតិនេះ ត្រូវរួមបញ្ចូលមន្ត្រីរាជការទទួលបន្ទុកការងារកុមារក្នុងរចនាសម្ព័ន្ធនិងក្រសួងស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អាជ្ញាធរមានសមត្ថកិច្ចតាមវិស័យពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់រហូតដល់ភូមិ ព្រោះពួកគេត្រូវតែទទួលបានការអប់រំទូលំទូលាយនិងបណ្ដុះបណ្ដាលអំពីបទដ្ឋានគតិយុត្តផ្អែកច្បាប់ នីតិវិធីអនុវត្តជាប្រព័ន្ធពហុវិស័យ ព្រមទាំងបទពិសោធជាក់ស្ដែងតាមករណី ដើម្បីឱ្យការអនុវត្តកិច្ចការពារប្រព្រឹត្តទៅដោយរលូននិងទទួលបានលទ្ធផលល្អទៅតាមប្រភេទកិច្ចការពារនីមួយៗ ជាពិសេសការបង្ការទប់ស្កាត់ក្នុងគ្រួសារដែលមាតាបិតាឬអាណាព្យាបាលទទួលបានពីការអប់រំផ្សព្វផ្សាយនេះ។

### ៤.៣.៣- ការកៀរគរធនធានហិរញ្ញវត្ថុ

ការកៀរគរធនធានហិរញ្ញវត្ថុពីគ្រប់ប្រភពរួមទាំងថវិកាពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន វិស័យឯកជននានា ជាយុទ្ធសាស្ត្រគន្លឹះសម្រាប់ឱ្យយុទ្ធសាស្ត្រនីមួយៗនិងសកម្មភាពដំណើរការទៅបាន។

ក្នុងផែនការសកម្មភាពជាតិនានានិងយុទ្ធសាស្ត្រដែលមានស្រាប់ពាក់ពន្ធ័នឹងកិច្ចការពារកុមារ សុទ្ធតែមានបរិយាយអំពីធនធានហិរញ្ញវត្ថុរៀងៗខ្លួន ដែលជាប្រភពរឹងមាំមួយសម្រាប់អនុវត្តយុទ្ធសាស្ត្រក្នុងគោលនយោបាយជាតិនេះ។ នៅក្នុងការកៀរគរធនធានពីគ្រប់ប្រភពផ្សេងៗ ចាំបាច់តម្រូវឱ្យរៀបចំផែនការថវិកា ដើម្បីអនុវត្តសកម្មភាពរួមគ្នាលើការងារកុមារ។

### ៤.៤- ក្នុងគោលដៅលើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្ដូរឥរិយាបថសង្គម ក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង យើងមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

### ៤.៤.១- ការលើកកម្ពស់ការយល់ដឹងអំពីការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ

យើងអនុវត្តនូវកម្រិតកិច្ចការពារបន្តបន្ទាប់ជាប្រព័ន្ធ តាមរយៈការលើកកម្ពស់ការយល់ដឹងទៅតាមកម្រិតដូចខាងក្រោម៖

- **កម្រិតទី១**: លើកកម្ពស់ការយល់ដឹងក្នុងចំណោមប្រជាជនទូទៅដែលពាក់ព័ន្ធទៅនឹងការទប់ស្កាត់ភាពងាយរងគ្រោះរបស់កុមារ រួមមានមាតាបិតាឬអាណាព្យាបាល ចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ អ្នកដឹកនាំសាសនា អ្នកស្ម័គ្រចិត្តតាមភូមិ អ្នកជិតខាង និងកុមារខ្លួនឯង។

- **កម្រិតទី២**: លើកកម្ពស់ការយល់ដឹងក្នុងចំណោមក្រុមគោលដៅ តួអង្គពាក់ព័ន្ធនឹងកុមារងាយរងគ្រោះ រួមមាន មន្ត្រីរាជការ(ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ) នាយកឬម្ចាស់សហគ្រាស គ្រឹះស្ថាននិងសិប្បកម្មនានា អង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍ កុមារអនាថា កុមារបម្រើការតាមផ្ទះ និងកុមារធ្វើការនៅកន្លែងគ្រោះថ្នាក់។

- **កម្រិតទី៣**: លើកកម្ពស់ការយល់ដឹងក្នុងចំណោមកុមាររងគ្រោះនិងគ្រួសារកុមាររងគ្រោះ។

ដើម្បីសម្រេចបាននូវការលើកកម្ពស់ការយល់ដឹងទៅតាមកម្រិតខាងលើ ក្រសួង ស្ថាប័ន អង្គការដៃគូ និងអ្នកពាក់ព័ន្ធ ត្រូវរៀបចំដាក់បញ្ចូលគ្រប់ការងារអាទិភាពដែលពាក់ព័ន្ធទៅនឹងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពរបស់ខ្លួននៅគ្រប់កម្រិត។

### ៤.៤.២- ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ

ការផ្លាស់ប្តូរឥរិយាបថសង្គម តម្រូវឱ្យដោះស្រាយឫសគល់នៃបញ្ហាកិច្ចការពារកុមារ (ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ពណ៌សម្បុរ ភេទ ភាសា នយោបាយឬទស្សនៈ ទ្រព្យសម្បត្តិ កំណើត ឋានៈនិងស្ថានភាពផ្សេងទៀត) ក្នុងទិសដៅផ្លាស់ប្តូរលទ្ធភាពកើតឡើងនៃករណីរំលោភបំពាននិងកេងប្រវ័ញ្ចលើកុមារ។ ដើម្បីឱ្យការអនុវត្តយុទ្ធសាស្ត្រនេះទទួលបានជោគជ័យ ក្រសួង ស្ថាប័ន អង្គការដៃគូ វិស័យឯកជន និងអ្នកពាក់ព័ន្ធត្រូវធ្វើការងាររួមគ្នាទៅតាមយុទ្ធសាស្ត្រនិងយន្តការដែលមានស្រាប់ក្នុងការកាត់បន្ថយហានិភ័យផ្សេងៗដែលកើតឡើងចំពោះកុមារ។

## ៤.៥- ចំពោះកិច្ចការពារកុមារឱ្យសមស្របតាមការជាក់ស្តែង ជាករណីដែលត្រូវការកិច្ចការពារមួយឬច្រើន តាមដំណាក់បន្តបន្ទាប់ឬនៅពេលតែមួយ ដែលយើងបានកំណត់ជាគោលដៅមួយត្រូវធ្វើសម្រេចទៅតាមគោលបំណងរបស់យើង យើងអាចដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

### ៤.៥.១- ការកាត់បន្ថយបញ្ហាប្រឈមជាអាទិភាពរបស់កុមារ

នៅក្នុងសង្គមសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន កុមារកម្ពុជាមួយចំនួននៅតែជួបភាពងាយរងគ្រោះជាបញ្ហាប្រឈមមួយចំនួនដូចជា ការធ្វើពលកម្មធ្ងន់ធ្ងរ ចំណាកស្រុក ការញៀនគ្រឿងញៀន ភាពអនាថា ភាពពិការ ការរងអំពើហិង្សា ការជួញដូរ ការទំនាស់នឹងច្បាប់ជាដើម។ ការជ្រើសរើសនិងកំណត់បានត្រឹមត្រូវនូវអាទិភាពរបស់បញ្ហាប្រឈមនៅក្នុងប្រព័ន្ធកិច្ចការពារកុមារ ទៅតាមវិស័យពាក់ព័ន្ធ ឬទៅតាមតំបន់ភូមិសាស្ត្រជាក់លាក់ អាចនាំឱ្យយើងសម្រេចបានលទ្ធផលល្អទៅតាមសូចនាករដែលយើងបានដាក់ចេញ ជាងការអនុវត្តទូទៅដែលគ្មានកំណត់អាទិភាព ឬការអនុវត្តគ្មានលក្ខណៈជាប្រព័ន្ធ។

ជាទូទៅ កុមារកម្ពុជារស់នៅជុំក្នុងគ្រួសារជាមួយឪពុកម្តាយ ឪពុកឬម្តាយ ឬជាមួយអាណាព្យាបាល។ អំពើហិង្សាក្នុងគ្រួសារដែលតែងកើតមាន ហើយស្ត្រីជាម្តាយតែងរងគ្រោះដោយអំពើហិង្សារបស់ប្តី មានផលប៉ះពាល់ប្រាកដដល់កុមារដូចជា ការភ័យរន្ធត់ ការរំលោភបំពាន ការខកខានមិនបានទៅសាលារៀនជាដើម។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ មានសារៈសំខាន់ណាស់សម្រាប់ការពារស្ត្រីនិងកូនៗរបស់ពួកគាត់។

### ៤.៥.២- ការអនុវត្តកិច្ចការពារបញ្ចូលគ្នា

នៅក្នុងសសរស្តម្ភទាំងបី មានការបង្ការទប់ស្កាត់ ការអន្តរាគមន៍ ការផ្តល់សេវានិងការឆ្លើយតបនៃកិច្ចការពារកុមារ វាមិននៅដោយឡែកពីគ្នាគ្រប់ករណីទេ។ ដូច្នេះ កិច្ចការពារកុមារត្រូវតែបានគិតជាប្រព័ន្ធ ទាំងការអនុវត្តច្បាប់ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធណាមួយ ទាំងក្រសួងស្ថាប័ននិងតួអង្គពាក់ព័ន្ធដែលត្រូវដោះស្រាយ ដូចជា

ករណីកើតមានការបង្ការទប់ស្កាត់ដែលត្រូវត្រៀមដល់កិច្ចអន្តរាគមន៍ ដែលការងារនេះត្រូវភ្ជាប់ជាមួយការផ្តល់សេវានិងការឆ្លើយតបជាមួយគ្នា ការបង្ការទប់ស្កាត់ក៏ត្រូវភ្ជាប់ជាមួយការផ្តល់សេវានិងការឆ្លើយតបផងដែរ។ ដំណោះស្រាយនេះវាទទួលបានប្រយោជន៍ច្រើន ហើយវាបានបញ្ចប់ករណីកិច្ចការពារមួយបានល្អថែមទៀត។

## ៥. ផែនការសកម្មភាព

ដើម្បីសម្រេចនូវយុទ្ធសាស្ត្រនីមួយៗដែលនឹងធ្វើឱ្យបានសម្រេចនូវគោលដៅទាំង៤ ដូចបានលើកឡើងខាងដើម យើងត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោម៖

### ៥.១. ការបង្កើតយន្តការ

ក្នុងគោលនយោបាយនិងផែនការជាតិនានានៃព្រះរាជាណាចក្រកម្ពុជាដែលយើងមាន មានរចនាសម្ព័ន្ធនិងយន្តការការងារផ្សេងៗគ្នាជាច្រើន ត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិឬថ្នាក់ក្រោមជាតិដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាដើម។ ក្នុងគោលនយោបាយនេះ ត្រូវពង្រឹងយន្តការដែលមានស្រាប់សម្រាប់សម្របសម្រួលលើដំណើរការកិច្ចការពារកុមារ ដើម្បីធ្វើឱ្យដំណើរការអនុវត្តយុទ្ធសាស្ត្រទាំងអស់និងផែនការសកម្មភាពទាំងឡាយ អាចសម្រេចបានទៅតាមគោលដៅរបស់យើង។

### ៥.២. ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ **ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល** មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យខ្លឹមសារក្នុងច្បាប់និងលិខិតបទដ្ឋានជាធរមានរបស់យើងឆ្លងកាត់តាមការអនុវត្តជាក់ស្តែង ដើម្បីរកចំណុចខ្វះខាតដែលប៉ះពាល់ដល់ការអនុវត្តកិច្ចការពារកុមារ ដែលឈានទៅលើកសំណើកែលម្អតាមនីតិវិធី ប្រសិនបើមានករណីចាំបាច់

- បច្ចុប្បន្ន ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារត្រូវបានធានា និងការពារដោយច្បាប់ពាក់ព័ន្ធដែលមានជាធរមានដូចជា ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទជាដើម

- យើងត្រូវសិក្សាដើម្បីឈានទៅបង្កើតច្បាប់ស្តីពីកិច្ចការពារកុមារ ដែលមានសមត្ថកិច្ចផ្ទាល់អាចការពារផលប្រយោជន៍កុមារបានច្រើនជាងមុន

- ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការចាត់វិធានការដើម្បីទប់ស្កាត់អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់ទម្រង់មកលើកុមារ គឺជាកត្តាចាំបាច់ក្នុងការជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ

- ក្នុងការបង្កើតក្របខ័ណ្ឌគតិយុត្តដើម្បីឈានទៅអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យបានល្អ ការងារដំបូងរបស់យើង គឺត្រូវធ្វើឱ្យមណ្ឌលថែទាំកុមារទាំងអស់មានចុះបញ្ជីត្រឹមត្រូវ និងត្រូវមានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួង ស្ថាប័នសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល មិនត្រូវទុកឱ្យមានកង្វះខាតដូចកន្លងមកទេ បើទោះបីជាមណ្ឌលថែទាំទាំងអស់នោះ បាននិងកំពុងរួមចំណែកក្នុងកិច្ចការពារកុមារក៏ដោយ។

### ៥.៣. ការគាំទ្រហិរញ្ញវត្ថុ

ចេញពីយុទ្ធសាស្ត្រនីមួយៗ ដែលយើងបានដាក់ចេញនូវផែនការសកម្មភាពមួយចំនួន ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយជាតិនេះ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័ន អាចប្រើប្រាស់ថវិការដ្ឋក្នុងក្របខ័ណ្ឌនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងកៀរគរមូលនិធិពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ និងពីប្រភពផ្សេងៗទៀត ដើម្បីធានាឱ្យបាននូវការអនុវត្តសកម្មភាពនីមួយៗដែលបានលើកឡើង។

### ៥.៤. ការបណ្តុះបណ្តាលធនធានមនុស្ស

ការបណ្តុះបណ្តាលធនធានមនុស្ស ត្រូវបានកំណត់ជាយុទ្ធសាស្ត្រមួយនៅក្នុងគោលនយោបាយជាតិរបស់យើង ព្រោះថា ធនធានមនុស្សដែលមានសមត្ថភាពនិងមានចំនួនគ្រប់គ្រាន់ ទើបការអនុវត្តគោលនយោបាយនៅគ្រប់លំដាប់ទទួលខុសត្រូវរបស់យើងអាចសម្រេចបានលទ្ធផលល្អ។ ផែនការសកម្មភាពសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស ត្រូវរៀបចំជាវគ្គផ្សេងៗ ដើម្បីលើកកម្ពស់ចំណេះដឹងនិងសមត្ថភាព ជាពិសេស អ្នកអនុវត្តផ្ទាល់នៅឃុំ សង្កាត់ ភូមិ សំដៅធានាការអនុវត្តកិច្ចការពារកុមារដូចមានកំណត់នៅច្បាប់និងលិខិតបទដ្ឋានរបស់យើង។

### ៥.៥. ដំណើរការអនុវត្តគម្រោង

ផែនការសកម្មភាពនីមួយៗដែលបម្រើឱ្យយុទ្ធសាស្ត្រ ត្រូវរៀបចំទៅតាមប្រភេទការងារផ្សេងៗគ្នា ដោយមានកំណត់រយៈពេលអនុវត្ត កំណត់ក្រសួងស្ថាប័នដឹកនាំឬអនុវត្តឱ្យបានច្បាស់លាស់ និងភ្ជាប់នូវសូចនាករមានលក្ខណៈអាចវាស់វែងបាន ការប៉ាន់ស្មានទំហំថវិកាត្រូវការដែលយើងអាចធ្វើការតាមដានត្រួតពិនិត្យនិងការវាយតម្លៃនៅពេលខាងមុខ។ គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមាររយៈពេល១០ឆ្នាំពីឆ្នាំ២០១៩ដល់២០២៩ អាចរៀបចំផែនការសកម្មភាពសម្រាប់៣ឆ្នាំ ៥ឆ្នាំ និងអាចបន្តដល់ចប់គោលនយោបាយជាតិទៅតាមប្រភេទកិច្ចការពារនីមួយៗ ដោយធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលអនុវត្តផែនការនីមួយៗ ដើម្បីធានាប្រសិទ្ធភាពអនុវត្ត។

## ៦. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ក្នុងការអនុវត្តគោលនយោបាយជាតិនេះ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃជាការងារពីរដែលបង្ហាញឱ្យឃើញនូវជំហានរីកចម្រើនជាបន្តបន្ទាប់ ដែលបានអនុវត្តក្នុងយុទ្ធសាស្ត្រនិងផែនការសកម្មភាពនីមួយៗ។ ផែនការសកម្មភាពនីមួយៗដែលបានដាក់ចេញ ត្រូវតែមានការតាមដានត្រួតពិនិត្យចាប់ពីចាប់ផ្តើមនៅឆ្នាំទី១ និងឈានទៅធ្វើការវាយតម្លៃនៅពេលចប់កាលកំណត់៣ឆ្នាំ ៥ឆ្នាំ ឬ១០ឆ្នាំរៀងៗខ្លួន ដើម្បីពិនិត្យមើលលទ្ធផលល្អដែលយើងទទួលបាននិងបញ្ហាប្រឈមត្រូវកែលម្អឬដោះស្រាយ ដោយប្រៀបធៀបទៅនឹងសូចនាករដែលមានកំណត់។ ក្នុងដំណើរការអនុវត្តគោលនយោបាយជាតិនេះត្រូវមានការវាយតម្លៃពាក់កណ្តាលអាណត្តិនៅឆ្នាំ២០២២ ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញនូវវិធានការចាំបាច់ថ្មីៗត្រូវអនុវត្តសម្រាប់៥ឆ្នាំបន្ទាប់ ដែលធ្វើឱ្យយើងឈានទៅសម្រេចបានលទ្ធផលល្អជាងមុន។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ចសម្របសម្រួលការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ និងរៀបចំរបាយការណ៍តាមផែនការសកម្មភាពនីមួយៗឱ្យមានលក្ខណៈជាប្រព័ន្ធនិងទាន់ពេលវេលា ដើម្បីសរុបការអនុវត្តនិងភាពអនុវត្តមាននៅក្នុងគោលនយោបាយជាតិនេះ។

## ៧. សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារមានចក្ខុវិស័យយូរអង្វែង ដែលអាចចាត់ទុកជាឯកសារប្រវត្តិសាស្ត្រមួយសម្រាប់កុមារកម្ពុជា បន្តពីក្រោយថ្ងៃ៧ មករា ១៩៧៩ ពេលដែលសិទ្ធិរបស់ប្រជាជនកម្ពុជាត្រូវបានរស់រានឡើងវិញក្រោយរបបប្រល័យពូជសាសន៍ ជាពិសេសសិទ្ធិកុមារដែលយើងបានយកចិត្តទុកដាក់ការពារ ដោយចាត់ទុកកុមារជាអ្នកបន្តវេនរបស់ប្រទេសជាតិ ដូចមានពាក្យស្លោកថា **«កុមារជាទំពាំងស្នងឫស្សី»** និង **«កុមារជាសសរទ្រូងសម្រាប់ប្រទេសជាតិ»**។

ប្រព័ន្ធកិច្ចការពារកុមារ គឺជាយុទ្ធសាស្ត្របង្ហាញអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធ្លាប់អនុវត្តកន្លងមក និងចាំបាច់ត្រូវធ្វើការពង្រឹងនិងពង្រីកបន្ថែមទៀត។ ក្នុងន័យបន្តនូវបុព្វហេតុនេះហើយ ទើបគោលនយោបាយជាតិនេះត្រូវបានរៀបចំឡើងជាដំបូង សម្រាប់រយៈពេល១០ឆ្នាំ ២០១៩-២០២៩ ដែលអាចប្រមូលផ្តុំការវិនិយោគរបស់យើងទៅលើកុមារ ទាំងស្មារតី ទាំងធនធាន ឱ្យមានលក្ខណៈជាប្រព័ន្ធគ្រប់ជ្រុងជ្រោយជាងមុន ដើម្បីឱ្យពួកគេគ្រប់គ្នាមានឱកាសស្មើៗគ្នាក្លាយជាធនធានមនុស្ស ដែលអាចរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិយើង។

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាច្រើននៅជាធរមានរបស់យើងដែលពាក់ព័ន្ធនឹងកុមារ ត្រូវមានតួនាទីនិងភារកិច្ចរៀងៗខ្លួននៅក្នុងប្រព័ន្ធមួយប្រទាក់ក្រឡាគ្នា ដែលអ្នកពាក់ព័ន្ធក្នុងនោះជាក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល សហគមន៍ គ្រួសារ បុគ្គលដែលអាចសម្រេចកិច្ចការពារយ៉ាងមានប្រសិទ្ធភាពនូវសសរស្តម្ភទាំងបីគឺ ការបង្ការទប់ស្កាត់ ការអន្តរាគមន៍ និងការផ្តល់សេវានិងការឆ្លើយតប។ ដូច្នេះ យើងមានការងារជាច្រើនត្រូវធ្វើសម្រាប់១០ឆ្នាំខាងមុខ ដែលតម្រូវឱ្យមានការវាយតម្លៃនៅពាក់កណ្តាលអាណត្តិនៃគោលនយោបាយ តាមការដាក់ចេញយុទ្ធសាស្ត្រសំខាន់ៗនិងផែនការសកម្មភាពត្រូវអនុវត្ត ដើម្បីធ្វើឱ្យសម្រេចគោលដៅដែលយើងបានរំពឹងទុក។

ផ្អែកលើគោលនយោបាយជាតិនេះ រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងកិច្ចការពារកុមារ នឹងរួមចំណែករៀងៗខ្លួនអនុវត្តឱ្យទទួលបានជោគជ័យ ដើម្បីជាឧត្តមប្រយោជន៍ដល់អនាគតកុមាររបស់យើង។

## ៨. សន្ទានុក្រម

**ប្រព័ន្ធកិច្ចការពារកុមារ** (Child Protection System) សំដៅដល់បណ្តុំនៃវិធានដែលបង្កើតឡើងក្នុងគោលបំណងជំរុញនិងលើកកម្ពស់ការការពារកុមារពីការរំលោភបំពាន ការមិនអើពើ ការកេងប្រវ័ញ្ច និងអំពើហិង្សា។

**ការបង្ការ** (Prevention) សំដៅដល់បណ្តុំសកម្មភាពនិងសេវាដែលត្រូវអនុវត្ត ដើម្បីបញ្ចៀសហានិភ័យផ្សេងៗកុំឱ្យកើតមានចំពោះកុមារ ដូចជា ការលើកកម្ពស់ការយល់ដឹង សមត្ថភាពជាទូទៅរបស់អ្នកពាក់ព័ន្ធនិងកុមារ ដើម្បីឱ្យខ្លួនគេក្លាយទៅជាម្ចាស់សិទ្ធិជាដើម។

**អន្តរាគមន៍** (Intervention) សំដៅដល់បណ្តុំសកម្មភាពដែលត្រូវអនុវត្តក្នុងកិច្ចការពារកុមារនៅពេលកើតមានហានិភ័យណាមួយចំពោះកុមារ។

**ការឆ្លើយតប** (Response) សំដៅដល់កិច្ចអន្តរាគមន៍នៅពេលហានិភ័យកើតឡើងចំពោះកុមារឬក្រោយពេលមានហានិភ័យ ទៅតាមប្រភេទហានិភ័យនីមួយៗ ដើម្បីស្តារសុខុមាលភាពរបស់កុមារវិញ។

**សុខុមាលភាពកុមារ** (Child Welfare) សំដៅដល់បណ្តុំសេវាដែលកុមារទទួលបានអត្ថប្រយោជន៍ខាងផ្លូវកាយ ផ្លូវចិត្ត សម្ភារៈ ដើម្បីឱ្យពួកគេអាចរស់មានផាសុកភាព សុវត្ថិភាព និងការអភិវឌ្ឍ។

**ភ្នាក់ងារសង្គមកិច្ច** សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងកិច្ចការពារកុមារ ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

**ការវិនិយោគកុមារ** សំដៅដល់ការបោះទុនដ៏ឆ្លាតវៃមួយមានរយៈពេលយូរដើម្បីអភិវឌ្ឍកុមារឱ្យចាកផុតពីភាពក្រីក្រ ភាពត្រូវគេរំលោភបំពានលើសិទ្ធិ ក៏ដូចជារូបរាងកាយ ភាពអវិជ្ជា និងការរស់នៅគ្មានសុខមាលភាព ក្នុងគោលបំណងធានានូវអនាគតដ៏ល្អរបស់កុមារ។

**វិធីសាស្ត្រតាមបែបប្រតិកម្ម** សំដៅដល់វិធី កម្រង ឬបែបផែនដែលមានរបៀបរៀបរយសម្រាប់ដឹកនាំធ្វើកិច្ចការអ្វីមួយ ដើម្បីតទល់ ឬឆ្លើយតបភ្លាមទៅនឹងស្ថានភាពអ្វីមួយដែលបានកើតឡើងហើយ។

**វិធីសាស្ត្រតាមបែបអវិជ្ជមាន** សំដៅដល់វិធីជំទាស់ដើម្បីឆ្លើយតបទៅនឹងអ្វីមួយដែលគេធ្វើមកលើយើងដោយបង្ខំដោយផ្ទុយពីឆន្ទៈរបស់យើង។ ជាធម្មតាការជំទាស់នេះមិនឆ្លើយតបទៅវិញភ្លាមៗទេ គឺធ្វើដោយភាពស្ងៀមស្ងាត់។ និយាយរួម វិធីសាស្ត្រនេះគឺដូចនឹងប្រតិកម្មបែបអវិជ្ជមានដែរ។

## ឧបសម្ព័ន្ធនៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ

| គោលដៅ | យុទ្ធសាស្ត្រ | រយៈពេល | ស្ថាប័នទទួលខុសត្រូវអនុវត្ត | ប្រភពថវិកានិងការចូលរួម |
|---|---|---|---|---|
| ៣.២.១- អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព | ៤.១- ក្នុងគោលដៅអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ | ឆ្នាំទី១-១០ | ក្រសួង ស្ថាប័ន ដែលជាសមាជិក ក.ជ.ក. | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| ៣.២.២- រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ | ៤.២- ក្នុងគោលដៅរៀបចំប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យទៅតាមប្រភេទកិច្ចការពារនីមួយៗ នៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធនឹងកុមារ | | | |
| | ៤.២.១- ការកំណត់អាទិភាពនៃកិច្ចការពារតាមលក្ខណៈភូមិសាស្ត្រ | ឆ្នាំទី២–៥ | ក.ជ.ក. | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| | ៤.២.២- ការកំណត់អាទិភាពនៃកិច្ចការពារតាមវ័យនិងភេទ | ឆ្នាំទី២–៥ | គណៈកម្មការការពារកុមារថ្នាក់ជាតិ ក្រសួង ស.អ.យ. និងក្រសួងផែនការ | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| | ៤.២.៣- ការកំណត់អ្នកទទួលខុសត្រូវនាំមុខនិងទទួលខុសត្រូវពាក់ព័ន្ធជាប្រព័ន្ធ | ឆ្នាំទី២–៥ | គណៈកម្មការការពារកុមារថ្នាក់ជាតិ | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| ៣.២.៣- អភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ | ៤.៣- ក្នុងគោលដៅកសាងធនធានមនុស្ស ទាំងសមត្ថភាពការងារក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងទាំងចំនួននៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធសម្រាប់កិច្ចការពារកុមារ ជាពិសេសនៅឃុំ សង្កាត់ និងភូមិ | | | |
| | ៤.៣.១- ការកសាងធនធានមនុស្ស | ឆ្នាំទី១ | ក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិនិងក្រសួង ស.អ.យ. | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |

| | | | | |
|---|---|---|---|---|
| | ៤.៣.២- ការអប់រំផ្សព្វផ្សាយនិងការបណ្តុះបណ្តាលបហ | ឆ្នាំទី១ | ក.ជ.ក. និង ក្រសួង ស.អ.យ. | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| | ៤.៣.៣- ការកៀរគរធនធានហិរញ្ញវត្ថុ | ឆ្នាំទី១ | ក.ជ.ក. ក្រសួង ស.អ.យ. ក្រសួងយុត្តិធម៌ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| ៣.២.៤- លើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ នៅគ្រប់ទីកន្លែង។ | ៤.៤- គោលដៅលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ នៅគ្រប់ទីកន្លែង | | | |
| | ៤.៤.១- លើកកម្ពស់ការយល់ដឹងអំពីការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ | ឆ្នាំទី១ | ក្រសួង ស.អ.យ. ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា គ.ស.ម.ក. និង អង្គការពាក់ព័ន្ធ | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| | ៤.៤.២- លើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ | ឆ្នាំទី១ | ក្រសួងធម្មការនិងសាសនា អាជ្ញាធរដែនដី និងគ.ស.ម.ក. | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| | ៤.៤.៣- លើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីកិច្ចការពារកុមារ | ឆ្នាំទី១ | ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងផែនការ | រាជរដ្ឋាភិបាល អង្គការដៃគូ និងវិស័យឯកជន |
| ៣.២.៥- ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង | ៤.៥- ចំពោះកិច្ចការពារកុមារឱ្យសមស្របតាមការជាក់ស្តែង ជាករណីដែលត្រូវការកិច្ចការពារមួយឬច្រើន តាមដំណាក់បន្តបន្ទាប់ឬនៅពេលតែមួយ ដែលយើងបានកំណត់ជាគោលដៅមួយត្រូវធ្វើសម្រេចទៅតាមគោលបំណងរបស់យើង | | | |
| | ៤.៥.១- ការកាត់បន្ថយបញ្ហាប្រឈមជាអាទិភាពរបស់កុមារ | | | |
| | ៤.៥.២- ការអនុវត្តកិច្ចការពារបញ្ចូលគ្នា | | | |

បោះពុម្ពដោយ៖ ឧបត្ថម្ភដោយ៖

បោះពុម្ពដោយ៖

ឧបត្ថម្ភដោយ៖

PLAN INTERNATIONAL

ChildFund Cambodia